ក្រុមប្រឹក្សារដ្ឋ

លេខ ០១ ក្រ

# សាធារណរដ្ឋប្រជាមានិតកម្ពុជា

## ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ក្រឹត្យ

# ក្រុមប្រឹក្សារដ្ឋ

## នៃ

## សាធារណរដ្ឋប្រជាមានិតកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

-បានឃើញ ច្បាប់ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៤ ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២

-បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៣ ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈឆ្នាំ១៩៨ ២

-បានឃើញគោលមាគ៌ានយោបាយសណ្តោសប្រោសប្រណីរបស់ បក្ស និង រដ្ឋ ស្តីពីការអប់រំ កែប្រែចំពោះពិរុទ្ធជន ក្នុងឱកាសថ្ងៃបុណ្យរំលឹកខួបអនុស្សាវរីយ៍លើកទី៥ ថ្ងៃកំណើតសាធារណរដ្ឋប្រជាមានិត កម្ពុជាតាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

**<u>សម្រេច</u>**

-មាត្រា ១ ត្រូវបានអនុគ្រោះបន្ថយទោស ឬ លើកលែងទោសចំពោះបណ្តាពិរុទ្ធជនដែលជាប់ពន្ធនាគារ ហើយបានកែប្រែល្អតាមបណ្តាលក្ខខណ្ឌដូចខាងក្រោមនេះ៖

១-ល័ក្ខខ័ណ្ឌសម្រាប់ពិនិត្យអនុគ្រោះ បន្ថយទោស ឬ លើកលែងទោស

ក-បានឆ្លើយសារភាពទោសកំហុសត្រឹមត្រូវតាមត្រង់ មានការសោកស្តាយ ហើយបានទទួលការកែប្រែដោយស្មោះបានប្តេជ្ញាចិត្តខិតខំកែប្រែឱ្យបានជាពលរដ្ឋល្អ សុចរិត ។

ខ-បានប្រកបការងារពលកម្ម រៀនសូត្រយ៉ាងសកម្ម មានឥទ្ធិពលល្អលើពិរុទ្ធជនដ៏ទៃទៀត ក្នុងការកែប្រែនិងមានការជឿនលឿន ។

គ-បានគោរពប្រតិបត្តិតាមយ៉ាងហ្មត់ចត់នូវបណ្តារបប បទបញ្ជាផ្ទៃក្នុង របស់មន្ទីរឃុំឃាំង។

ង-អំពីថេរៈវេលជាប់ពន្ធនាគារ សម្រាប់ពិនិត្យអនុគ្រោះ បន្ថយរយៈពេលជាប់ពន្ធនាគារ ឬ លើកលែងទោស ។

ច-ពិនិត្យអនុគ្រោះបន្ថយរយៈពេលជាប់ពន្ធនាគារ ចំពោះបណ្តាពិរុទ្ធជន ដែលបានកែប្រែត្រឹមត្រូវតាមលក្ខខណ្ឌដូចបានពោលខាងលើ ក្រោយពីបានជាប់ឃុំឃាំងក្នុងពន្ធនាគារអស់រយៈពេលយ៉ាងតិចមួយភាគប្រាំ នៃកម្រិតនៃទោស ។

-ចំពោះទោសអស់មួយជីវិត គឺត្រូវជាប់ឃុំឃាំងក្នុងពន្ធនាគារបានប្រាំឆ្នាំយ៉ាងតិច ។

ខ-ពិនិត្យអនុគ្រោះលើកលែងទោស ចំពោះបណ្តាពិរុទ្ធជន ដែលបានកែប្រែត្រឹមត្រូវតាមលក្ខខណ្ឌដូចបានពោលខាងលើ ក្រោយពីបានជាប់ឃុំឃាំងក្នុងពន្ធនាគារអស់រយៈពេលយ៉ាងតិចពាក់កណ្តាលកម្រិតទោស ។

មាត្រា ២ ត្រូវបានពិនិត្យអនុគ្រោះលើកលែងទោស ចំពោះបណ្តាជនមានទោសឯទៀត ដែលត្រូវបានចាប់ខ្លួនឃុំឃាំង ហើយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចពោលក្នុងចំណុច ១ ខាងលើ ។

មាត្រា ៣ ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលប្រតិបត្តិក្រឹត្យនេះ អោយមានប្រសិទ្ធិភាពល្អ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៨៤

ជ-ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និងត្រា

**ហេង សំរិន**